# រឿង មហាចោរនៅទល់ដែន

## ភាគទី៤៧ (ស្នេហាលើទូក)

នាងកែវមណីឡើងស្ទាំងបបូរមាត់។ មានន្ទអីក៏ដឹងចិត្តនាងម៉្លេះ?

ឱ! អស់ហើយ គ្រោងការណ៍សម្ងាត់របស់នាង។ ជីតាឃើញជាក់ជារត់មិនរួចជាដាច់ខាត។ ចាំ! ដល់កន្លែងនោះ អូនហៅតម្រួតឱ្យជួយជាធម្មតាទេ ព្រោះបងចាប់អូន។ តើបងធ្វើម៉េចទៅ?

មុនដល់កន្លែងនោះ បងឱ្យអោយអូនលេបថ្នាំងងុយដេក ឲ្យអូនគេងលក់ រួចបងកំហែងតម្រួតថាកុំឲ្យឮមាត់អម្ចាស់ពួកឯងដេកលក់។ ព្រះនាងត្រូវការទៅទល់ដែនទៅរកមហាចោរ។ អូនឃើញទេធ្វើយ៉ាងនេះអូនទៅណារួច?

ចាំះ! ចាំះ! អូនគិតរត់បែបនោះមែន!

ថាហើយ នាងប្រះខ្លួនទន្ទឹមនឹងមានន្ទ រួចឱបបុរសហយ៉ាងតឹងនិយាយតទៅទៀតថា:

បងប្រាជ្ញាមែន តែចាំមើលអូនរត់ឲ្យរួចពីកណ្ដាប់ដៃមហាចោរកំណាច។

មានន្ទសើចរួចក្រោកអង្គុយអុជបារីមួយទៀត បង្ហុយផ្សែងផ្ងោម ជីតាក្រោកតាមអង្គុយប្រកៀកជាប់ជិតនឹងមានន្ទ។ និយាយថា:

ក្នុងជាតិនេះ ប្អូននៅតែស្រលាញ់ "មហាចោរ" តែមួយនេះដែលប្ញន់នគរ ដែលជួយជាតិដែលដោះទុក្ខប្រជាជន? តែប្អូនមិនចង់បានយកធ្វើជាប្ដីទេ ព្រោះចិត្តគេខ្ពស់ណាស់ ប្អូនឈោងមិនដល់ផ្ញើមិនដូចតាមមិនទាន់...

មានន្ទឱបនាងលើកស្រីបីត្រកង រួចដាក់បណ្ដោយទៅលើគ្រែ

គេងទៅអូន បងលាហើយ

អញ្ជើញ អូ! ឈប់សិន...

នាងស្ទុះក្រោកឡើង ស្ទុះលោតពីលើគ្រែទៅឱបក្រញីមានន្ទដែលញញឹមជានិច្ចរួចនាងផ្តួលខ្លួនលើដៃជាសញ្ញាលាគ្នារួចបិទភ្នែក។

អត្ថបទដោយ៖ មាស សុភាព

មានន្ទថយខ្លួនមួយៗ ចេញពីធីតា រួចនិយាយជាចុងបង្ហើយថាៈ

បងទុកទ្វារចំហឲ្យអូនរត់ទៅតាមខ្យល់ចុះ។

នាងមណីលើកដៃ មានន្ទលើកដៃ រួចជនទាំងពីរក៏បែកគ្នាទៅ។ ចោរដេកសម្ងឹងមើលផ្កាយលើដំបូលទូក។ ធីតាលបស្តាប់នាយអាយ គ្មានឮសូរក្រៅពីដង្ហើមជនអ្នកដេកលក់នោះប៉ុណ្ណោះ។ កញ្ញាខ្ទួលខ្ទាញ់រួចរីករាយក្នុងចិត្តយ៉ាងក្រៃអនេក។ នាងដើរលបៗ លើកជើងឡើងក្តារទូកខាងក្រោយ។ នាងបម្រុងដែលកំពុងអង្គុយកាច់ចង្កូត ងោកផ្ងក់ភ្ញាក់ដូចគេកន្ទ្រាក់ហៀបស្រែក តែម្រាមដៃដ៏ទន់ភ្លន់របស់ព្រះនាងខត្តិយ៉ាណី ខ្ទប់បបូរមាត់ដែលហៀបនឹងស្រែកឡើងនេះជាប់។ បុរសភ័យក្តុកៗ ដកដង្ហើមធុំក្លិនក្រអូបសាយពីម្រាមដៃដ៏តូចប្រឡឹងនេះ។ ទ្រូងអ្នកញ័ររន្ធត់ស្ទើរធ្លាយជាពីរបី។ ញើសស្អិតៗ បែកញើសពីខ្នងអ្នកទាំងក្នុងរាត្រីដ៏ត្រជាក់នេះ។

ព្រះនាងឈរប្រចត់កែងដៃ ផ្ទេរខ្លួនយ៉ាងទន់ភ្លន់នៅជិតត្រចៀកបម្រុងខ្សឹបថាៈ

កុំអោយបងនិយាយខ្លាំងអី!

អូយ! ពាក្យបង...បង...បងមួយម៉ាត់នេះថ្មីអ្វីក៏ថ្មីម្ល៉េះ?

ពាក្យនេះមានទម្ងន់ប៉ុនភ្នំព្រះសុមេរុមកលើចិត្តកម្លោះ។ បើកាត់ជាតម្លៃពាក្យនេះថ្លៃរាប់កោដិរៀល។ អស្ចារ្យមែន! លោតែនាងហៅមាណពយើងបង បង...។ ពាក្យមួយម៉ាត់នេះឮសូរពីរយដងក្នុងមនោសញ្ចេតនាអ្នកកាច់ចង្កូតយើង។ បុរសហាក់ឃើញថា រូបអ្នកថ្លៃផុតអស់ប្រុសឯទៀត។ ត្បិតធីតាមួយក៏ល្អផុតអស់នារី មកសុំខ្លួននៅពីក្រោមអ្នក។ ឱ! សំណាងអីក៏ធំម្ល៉េះ! កំពុងភ្លឹកក្នុងការផ្ងុយ ព្រះអាទិត្យមួយរះឡើងបំភ្លឺព្រលឹងមាណពឲ្យភ្លឺរីករាយឡើងនឹងតណ្ហាដែលហូរកំហុកយ៉ាងខ្លាំង ស្ទើរភ្លេចអស់ករណីកិច្ចដែលកំពុងធ្វើ។ ខ្វះការអប់រំដូចអ្នកតស៊ូឯទៀត មាននាយកោប មហាកាល វីរៈ អារុណ ជាដើម មនោគតិរបស់នាយបម្រុងជ្រុលយ៉ាងលឿនគ្មានអ្វីទប់ឡើយ។ បុរសក្រឡេកមើលនាយអាយ សំលឹងមើលទៅអ្នកទូកអស់ឃើញលក់ស្កប់ស្កល់។ ជយោ! ពេលវេលាក៏ចេះជួយសេចក្តីស្នេហា រវាងជនកំសត់ម្នាក់ជាមួយព្រះនាងខត្តិយ៉ាណីមួយអង្គដែរ។ នាយបម្រុងត្រិះរិះថា "ឥឡូវគេហៅអញបង តើអញ

ហ៊ានហៅគេអូនឬទេ? ទេ! ទេ! មិនសមទេឯងជារាស្ត្រសាមញ្ញនេះ គេជាស្ដេច! ឱ! ឃើញខុសគ្នាឆ្ងាយណាស់" អភ័ព្វជញ្ជាំងវណ្ណៈ។

បុរសប្រឹងទប់ចិត្តអ្នកដែលបុកជ្រួលឡើងខ្លាំង ដោយជាប់ចិត្តខ្សឹបតបវិញថា:

អ៊ី ព្រះនាងមិនទាន់ផ្ទុំទេ?

នារីញញឹមឆ្លើយយ៉ាងត្រជាក់ដល់បណ្ដូលចិត្តថា:

ចាំះ! ខ្ញុំមិនទាន់ទទួលដំណេកទេ ខ្ញុំអផ្សុកណាស់

ខាងក្នុងក្ដៅណាស់ទៅឬអី?

បាទ! បាន មានអីទាន តែប្រយ័ត្នក្រែងលោកគ្រូឃើញ។

សំឡេងជីតាយ៉ាងគ្រលួចរីតតែពិរោះឆ្លើយទៀតថា:

មិនអីទេ! បើបងខ្ញុំភ្ញាក់ ខ្ញុំរត់ទៅវិញភ្លាម ខ្ញុំមិនឲ្យបងព្រួយទេ។

ជនទាំងពីរក៏នៅស្ងៀម ហាក់អស់សំដី និយាយរកគ្នា។ នាងមណីរិះរករឿងនិយាយទៀតថា:

យី! ខ្យល់ខាងក្រៅរហើយត្រជាក់ស្រួលណាស់ហ្ន៎។

ខ្ញុំរងាណាស់ អ្នកនាងមិនរងាទេឬ?

ចាំះ! ឥឡូវរងាដែរ។

ពាក្យនេះ ធ្វើឲ្យទឹកចិត្តបុរសកម្លោះឡើងប៉ឹតប៉ោងរឹតតែខ្លាំងជាងមុនទៅទៀត។ បុរសជឿជាក់ថា ល្វាចកំសត់នេះជាល្វាចពិសេសដែលអ្នកជាមនុស្សទន់ខ្សោយបានស្នេហាស្រ្តីម្នាក់ដ៏ខ្ពង់ខ្ពស់បំផុត។ បុរសលួចញញឹមសង្ឃឹមទុកថា ចំណងស្នេហារបស់អ្នកមុខជាបានសម្រេចក្នុងមួយពេលដ៏ចន្លោះនេះមិនខាន។

**(សូមរង់ចាំតាមដានភាគទី២៨ នៅសប្ដាហ៍ក្រោយ)**

អត្ថបទដោយ៖ មាស សុភាព